ខ្ញុំគ្រាន់តែជាប៉ូលិសក្រុងតូចទាបគ្មានឋានៈម្នាក់ដែលសែនឪប្រេស រស់នៅធុញទ្រាន់ចំពោះរឿងដដែលៗនៃជីវិតខ្លួនឯង ហើយឆ្អួតចិត្តរង់ចាំមនុស្សអច្ឆរិយក្នុងក្តីស្រមៃ។ សូម្បីតែប្រាថ្នាចង់បានអ្វីមួយពិសេសឱ្យកើតឡើងចំពោះបេះដូងសាបគ្មានជាតិនេះ ក៏មិនដឹងថា បំណងប្រាថ្នារបស់ខ្ញុំជាអ្វី?

អ្វីទៅឱ្យខ្ញុំត្រេកត្រអាលបាន?

វិទ្យុទាក់ទងបានលាន់សំឡេងមក៖

« Jessie ឮហៅឆ្លើយៗៗៗៗ! កំពុងធ្វើអ្វី? កំពុងដើរការពារដើមពោតលាស់ត្រួយនៅខាងកើតក្រុង?»

ជាធម្មតាទៅហើយដែលគេទុកខ្ញុំសម្រាប់ប្រមាថឡកលើយ សូម្បីពីអ្នកបញ្ជូនព័ត៌មានតាមអាយកូមក៏ហ៊ានលេងសើចបែបនេះដែរពេលដែលខ្ញុំកំពុងបំពេញកាតព្វកិច្ច។

តែខ្ញុំមិនយកពេលទៅខូចចិត្តជាមួយបាតសង្គមទាំងនេះទេ។

ខ្ញុំដើរល្បាតចុះឡើងជាមួយអារម្មណ៍មួយភ័យៗ.....អ្នកប្រហែលជាមិនដឹងទេថា នេះជាព្រះចន្ទពេញបូណ៌មីហើយ ព្រះចន្ទចេញសញ្ញាណឈាម.....ជាព្រះចន្ទពណ៌មាសក្រហមង៉ូវ.... ខ្ញុំសូមស្បថថា វិញ្ញាណទី៦របស់ខ្ញុំឱ្យសញ្ញា.....

បប្ញូរមាត់របស់ខ្ញុំញ័រព្រោះរងា។ ខ្ញុំដើរឱបដៃសំដៅប៉ូលិសស្រីវ័យចំណាស់ម្នាក់ដែលគ្មានអ្នកណាចូលចិត្តគាត់ទេ។ គេមិននិយាយរកគាត់សូម្បតែឈរទិញបីហ្គីក្បែរគ្នា។ យប់នេះស្រាប់តែគាត់ដើរមកប៉ះកន្លែងខ្ញុំល្បាត។

«អ្នកមីងហ្សេដា»

ខ្ញុំហៅគាត់។ មនុស្សដែលត្រូវគេមើលងាយនិងចាត់ថ្នាក់ទុកឱ្យខ្ញុំជាអ្នករាប់ក៏បាន។

គាត់ឈ្មោះហ្សេដាហាប់មិន មានអាយុចិតសិបប្រាំ! មានជីវិតអានាថាឥតពំនឹង គ្មានប្តីឬកូន រស់នៅចម្អែតក្រពះដោយការផឹកស្រា និងជក់បារីសម្លាប់ពេលវេលា។

«ភាពឆ្កួតៗ ដូចជាកំពុងតែត្រៀមរៀបចំលេចមកទទួលយើង!»

គាត់ខ្សឹបហើយសម្លឹងមេឃ។ ហេតុណាស់គាត់មានជីវិតមួយដែលត្រូវគេមាក់ងាយដូចខ្ញុំណាស់ ហើយមានពិភាល់ពីសម្រាប់ព្រះចន្ទពណ៌ក្រហមដូចខ្ញុំទៀត?

«តើមានអ្វីនៅក្នុងហ្នឹងខ្ញុំសួរ!»

«ឋាននរក»

គាត់រអ៊ូជាមួយនឹងកន្ទុយបារីទើរលើបប្ញូរមាត់ជ្រួញជ្រីវ។

«ព្រះចន្ទពេញលេញពីរដងក្នុងខែតែមួយ កម្រណាស់កូន! វាមានថាមពលខ្លាំង! ប្រសិនបើវិញ្ញាណយើងអាចចូលទៅស្រូបពន្លឺពិតនៅជម្រៅខាងក្នុងវា!»

ខ្ញុំងក់ក្បាល តែក៏ផ្អៀងក ផ្ទៀងសម្លឹងជុំវិញនេះ ថាមានអ្នកណាឃើញពីរនាក់យើងនិយាយពីរឿងឡប់ៗបែបនេះដែរទេក្នុងនាមប៉ូលិសស្រីចម្លែកដូចគ្នា។

ជីវិតជាអ្នកល្បាតក្នុងតំបន់ព្រៃភាគខាងជើងនៃរដ្ឋ Wisconsin ដែលជាសីមាអាថ៌កំបាំងបន្សល់ទុកពីប្រជាជាតិ Ojibwe ខ្ញុំតែងបានឮ និងជក់ចិត្តលើបណ្ដារឿងព្រេងនិទាន woo-woo (ជំនឿខ្វះមូលដ្ឋានវិទ្យាសាស្ត្រខាងវិញ្ញាណ)។

ប្រជាជនខ្លះតែងតែខឹងខ្ញុំដែលនិយមរស់នៅក្នុងពិភពទំនើបមួយ ទាំងការប្រព្រឹត្ត និងការនិយាយការពន្យល់ពួកគេថា រឿងព្រេងទាំងនោះគ្មានកន្លែងណាសមជាមួយ ប្រវត្តិសាស្ត្រយើងឆ្លងកាត់ទេ។ ដើម្បីធ្វើការងាររបស់ខ្ញុំឱ្យបានល្អ ឱ្យពួកគេផ្លាស់ប្ដូរផ្នត់គំនិត ខ្ញុំត្រូវការ«ការពិតមកបង្ហាញ»។ ងាកទៅម្ខាងរកតែនឹងនិយាយគ្នាលេងអំពីរឿងវិញ្ញាណ អ្នកស្រីហ្សេដា ទ្រេតជញ្ជាំងការិយាល័យនិងស្រម៉ុកដោយមិនត្រូវការភួយដណ្ដប់។

មេឃរងាឡើងៗ ខ្ញុំគិតថាអាណិតគាត់ ក៏ចូលទៅក្នុងបន្ទិច ស្វែងរកក្រែងមានអីមកគ្របដណ្ដប់ឱ្យ។ ចេញមកវិញជាមួយខ្នើយសាឡុងធំមួយ ទន់តែក្រាស់ខ្ញុំបាត់គាត់ពីកន្លែងនោះ។

«យើងមានបញ្ហាហើយ កូនស្រី!»

គាត់កំពុងនៅខាងក្រោមនឹងរៀបចំចង្កេះខោដ៏ធំម៉ាប់ញ៉ុកខ្សែក្រវាត់។

«តើមានបញ្ហាអ្វី?» ខ្ញុំបានទម្លាក់ខ្នើយចោល ស្ទុះទៅក្បែរឡានបើកភ្លើងក្រហមនិងត្រៀមស៊ីរ៉ែន។

«ខ្ញុំហ្សេដាហាប់មិន! ឮហើយទទួលៗ» គាត់មិននិយាយរកខ្ញុំបែរជាវាយវិទ្យុទាក់ទង ស្រែកដដែលៗច្រើនដងក្រោមអាកាសធាតុរងាញាក់។ នៅលើមេឃពពកហើរខ្ជូលព័ទ្ធពេនជុំវិញព្រះចន្ទពណ៌ឈាម។

ខ្ញុំមានគម្រោងសាកសួរ ប៉ុន្តែហ្សេដាបានទទួលការឆ្លើយតប។ ពេលខ្លះមានអារម្មណ៍ថាគាត់មានអាការៈភ័យខ្លាចជាងអ្វីដែលខ្ញុំធ្លាប់បានឃើញគាត់ធ្វើរាល់ដង។

មានរឿងអ្វី?

ខ្ញុំកើតចិត្តសង្ស័យ។ វាជាចិត្តខ្ញុំតែខ្ញុំមិនឱ្យក្លាយជាបញ្ហាការងារទេ។ ខ្ញុំតែងមានអារម្មណ៍បែបនេះពេលព្រះចន្ទពេញវង់និងមានពពកអមមកលឿនខ្ជូល តែយប់នេះហ្សេដាដូចជាមានបញ្ហាជាងខ្ញុំទៅទៀត។

«នៅចុងបឹងៗ» គាត់ស្រែកប្រាប់អ្នកម្ខាងទៀតនៃវិទ្យុទាក់ទង។ ដោយសារខ្ញុំឃើញថា សភាពការណ៍មិនល្អ ខ្ញុំឡើងឡានមុន ហើយគាត់រត់មកចូលដែរ។ ដៃគាត់ចុចស៊ីរ៉ែន ហើយខ្ញុំក៏ថយរីយ៉ែរឡានចេញ ក្នុងទិសដៅពីផ្លូវជាតិលេខ១៩៩ ឆ្ពោះទៅមាត់បឹង។

កណ្តាលផ្សែងរងា ខ្ញុំនិងមេតម្រួត រួមជាមួយប៉ូលិសប្រាំមួយនាក់ទៀតដែលហ្សេដាហៅមុននេះ បានជុំគ្នាក្បែរចុងបឹង បូករួមយុវវ័យដែលមិនទុកឱ្យរដូវក្តៅរំលងទៅទាំងគ្មានរឿងបាន ពួកគេជាពួកអ្នកទេសចរផ្សងព្រេងដ៏ឈឺក្បាលសម្រាប់ប៉ូលិស ពួកគេតែងគិតថាស្លាប់វិលល្ងាច។

និយាយមែន ខ្ញុំស្អប់រដូវក្តៅ។

នេះមិនទាន់ពីពួកសេដ្ឋីល្ងីល្ងើ មកពីទីក្រុងនានាដែលធុញចំពោះចរាចរណ៍និងការរស់នៅក្នុងប្រអប់ បានធ្វើដំណើរស្វែងរកបឹងនិងព្រៃ ដើម្បីលើស្លឹកងាប់ក្រោមក្បែរបឹងហើយខ្លះមករួមភេទលើនោះ។

ឥឡូវនេះត្រូវដាស់ឡើងកណ្តាលយប់ គង់ពួកគេត្រូវលាត់ កូនៗរបស់ពួកគេស្រែកយំ ឆ្កែពួកគេលូដាក់ព្រៃ អ្នកមានខ្លះ បើកទូកវ៉ាលឿនវេរចុះឡើងរំពងដែនវារី។

ពួកមិនចេះចំណាយប្រាក់! និងឥតបានការ!

ខ្ញុំក្តាប់ពិលនឹកជេរនិងដៃមួយដែលនៅសល់ក៏មកក្តាប់លើកាំភ្លើងព្រមគ្នា។

ជាការរំខានដូចជាធម្មតាសម្រាប់ពួកគេ ហើយគិតថាប៉ូលីសជាបរិវារ។

ហ្សេដាកេះខ្ញុំ៖

«តោះ! យើងទៅ! ខាងលើ មានរឿងមែន!»

គាត់មិចភ្នែក និងបាននាំខ្ញុំឡើងលើភ្នំចោលមាត់បឹង។

ខ្ញុំជាន់ហ្វ្រាំងងឹតព្រោះពីចម្ងាយ រថយន្ត SUV ប្រណីតដែលបើកជាប់ទើរលើចំណោត ចង្កៀងនៅឆាបឆេះ តែមិនឃើញម្ចាស់....ហេតុអ្វីបានជាម្ចាស់មិនបានទាញរថយន្តនោះចេញពីផ្លូវ យីៗ! ជួបមនុស្សល្ងង់ច្រើនពេកហើយយប់នេះ។

ខ្ញុំបានរីយ៉េរ រុញរថយន្តរបស់ខ្ញុំចេញពីផ្លូវ និងបញ្ចប់នូវសំឡេងស៊ីរ៉ែនដ៏ថ្លង់ដូចសំឡេងស្រែកថ្ងូរ។

«ចែកផ្លូវគ្នាមើល!»

គាត់លោតចុះទៅ ហើយបាត់ស្រមោលក្នុងស្បែរាត្រី។ ខ្ញុំនៅតែយឺតយ៉ាវណាស់ប្រៀបនឹងមនុស្សចាស់ដូចហ្សេដា។ ឃ្លុបស្បែកជើងកវែងរបស់ខ្ញុំជាន់រអិលមកលើផ្លូវកៅស៊ូ និងបញ្ចេញជាសម្រិបជើងលាន់ដូច ខ្មោចដើរបន្លាច។

ចង្កៀងឡានខាងមុខរបស់ខ្ញុំ បានបំភ្លឺពីទិដ្ឋភាពក្រោមអ័ព្ទ ដែលនៅទីនោះពិតជាមិនឃើញមានមនុស្សណាម្នាក់នៅក្នុងកៅអីខាងបើកបរនៃរថយន្តជាប់គាំងនោះទេ។

ម្ចាស់វាទៅណា?

“សួស្តី?” ខ្ញុំបានស្រែកហៅព្ញៗទៅភ្លាម។ គ្មានការឆ្លើយតប។ ខ្ញុំប្រញាប់ដើរព័ទ្ធមួយមុខរថយន្តគៀង ដោយយកបំណែកនៃភ្លើងពិលមកពិនិត្យ។ អូយស្តាយ! សម្រាប់រថយន្តដែលមានតម្លៃមិន

ក្រោម៤០,០០០ ដុល្លារនេះមិនដឹងវាបានពើបនឹងហេតុការណ៍អ្វីបានជា បែកជាដុំៗយ៉ាងងាយបាន?

តាមធម្មតាវាមាំណាស់ មុខរបស់វា។

«សូមកម្លាំងពិនិត្យឡើងមកលើភ្នំ! មានរបស់ត្រូវស្ទួចចុះ! ឡានមួយគ្មានឃើញមនុស្ស!»

ខ្ញុំហៅវិទ្យុខណៈការសម្លឹងមើលរបស់ខ្ញុំ បានរំកិលយឺតៗទៅទើរប៉ះតំណក់ឈាមដែលប្រែជាពណ៌ខ្មៅក្រោមពន្លឺព្រះចន្ទពណ៌ប្រាក់។ ចិត្តខ្ញុំអណ្តែតទៅឆ្ងាយ។ មិនថានៅខាងណោះ សួរអ្វីមកវិញតាមវិទ្យុ ខ្ញុំមិនបានឮទេ។ ខ្ញុំបានចំណាយពេលមួយនាទី ដើម្បីរត់ពិនិត្យជុំវិញទីសង្ស័យរកមើលសញ្ញាណាមួយនៃសត្វរបួសឬមនុស្ស ប៉ុន្តែមិនមានអ្វីសោះ។

ត្រលប់មកដល់រថយន្តវិញ ខ្ញុំបានសម្រេចទាញបើកទ្វារឡានពិនិត្យខាងក្នុង.....ខ្ញុំត្រូវព្រិចភ្នែករិះឈានថយក្រោយ ព្រោះរកឃើញនារីសែនក្មេងម្នាក់ ដែលនៅទ្រេតពួនលាក់ខ្លួនពីក្រោយចង្កូត នាងតូចដល់ថ្នាក់មើលពីក្រៅមិនឃើញ។

«ម៉េចហើយ? អូខេទេ?»

នាងមិនឆ្លើយ។ នារីតូចនេះមានស្នាមជាំនៅលើថ្ងាស ហើយភ្នែកដែលមើលមកខ្ញុំ ហាក់មានសភាពស្លន់។ នាងក្មេងខ្លាំងតែស្អាតណាស់ ជាសម្រស់ប្រភេទព្រះនាងទេពអប្សរទាំងសាច់ឈាមឈុតនាងស្លៀក អាចថា នាងតូចពេកក្នុងការបើកបរយានជំនិះទំហំនេះ ប៉ុន្តែអាចទេ ពួកជំទង់កូនអ្នកមាន?

ខ្ញុំបានគ្រវីក្បាលហួសចិត្ត។ ទេ! វាជាប្រទេសសេរី ខ្ជិលនិយាយ ហើយយើងជាអ្នកបម្រើពួករស់នៅក្នុងប្រទេសសេរីដែលតែងតែចង់បានធ្វើអ្វីៗប្លែកៗស្រេចក្បាលវ៉ាល់។

ពោងសុវត្ថិភាពមិនបានដាក់របើកមកទេ ដែលមានន័យថា រថយន្តមិនបានទង្គិចនឹងអ្វីជាដុំកំភួនសោះចុះម៉េចបែកផ្នែកខាងមុខ?

នាងស្រាប់តែបិទភ្នែករកកលតែនឹងសន្លប់ក្រោយឃើញខ្ញុំ។

«ហេ្យដាៗៗៗ»

គ្មានចម្លើយ។ ខ្ញុំងាកមករកក្មេងជំទង់វិញ។ អាចថានាងមានរបួសគ្រាំក្រោយការប៉ះទង្គិចនេះ ហើយសភាពពេលនេះបង្ហាញថា នាងមិនបានពាក់ខ្សែក្រវាត់សុវត្ថិភាពទេ។ អាម៉ាស់ជំនួសជនជាតិអាមេរិកវ័យក្មេងផ្សេងទៀត ខ្ញុំគិតទាំងសៅហ្មង។ ការបំពានច្បាប់បើកបរនៅក្នុងរដ្ឋនេះ ពិបាកបន្តិចក្នុងការបញ្ចប់ប្រសិនមនុស្សវ័យក្មេងបន្តអាវ៉ាសែ។

«អូខេ?» ខ្ញុំព្យាយាមម្តងទៀត ពេលនាងបន្តសម្លឹងមកខ្ញុំដោយមិនឆ្លើយរួច។

«តើអ្នកឈ្មោះអ្វី?»

ព្រះនាងតូចនេះ លើកដៃឡើងមកលើបង្ហាញខ្ញុំដោយ ទឹកមុខឈឺចាប់ ។

«ខារ៉ែនឡាសុន Karen Larson»

ខ្ញុំមិនបានចាប់អារម្មណ៍នឹងឈ្មោះនាងទេ ព្រោះទើបនឹងឃើញមានឈាមស្រក់ចុះឆ្វាចតាមបណ្ដោយកំភួនដៃរបស់នាង។ កញ្ចក់គ្មានខូចត្រង់ណាឡើយ លើកលែងតែនៅខាងមុខរថយន្តដែលទំនងជាបុកពីក្រៅ តើរលាត់ឈាមដោយរបៀបណា?

ខ្ញុំរុញពិលទៅកៀកផ្ដោតលើកំភួនដៃនាង។ ព្រះ! មានអ្វីមួយមែន! មុខរបួសនេះមានទំហំប៉ុនស្នាមខាំដោយចង្កូម វាស្ថិតនៅរវាងពីទៅមេដៃ និងកដៃរបស់នាង ម្ដុំថ្លើមដៃ។

«ត្រូវនឹងស្អី?» ខ្ញុំសួរទាំងរន្ធត់និងត្រៀមគិតអំពីវិធីទប់ទល់នឹងសត្វព្រៃកំណាចធំៗ។

«ចចក! វា.....ជាមនុស្សចចក»

ពួកគេមើល Netflix ច្រើនពេកហើយខ្ញុំគិត។ ត្រូវមើលទឹកនោមពួកគេ និងរកសារធាតុញៀន។ តែស្នាមរបួសនៅទីនេះជាការពិត។ ចិត្តខ្ញុំរារែក។ ភាពរន្ធត់នៅក្នុងគ្រាប់ភ្នែកនាងទាំងសងខាងនៅឡើយ។ ខ្ញុំលើកវិទ្យុទាក់ទងស្រែក «សុំជំនួយៗ! លើភ្នំ! ឡើងមកឥឡូវ!»

សំឡេងយំរ៉ោង ពីចម្ងាយនៃស៊ីរ៉ែនប៉ូលិស បានបក់កាត់ខ្យល់រាត្រីដ៏ត្រជាក់អនុញ្ញាតឱ្យខ្លួនខ្ញុំដកដង្ហើមធូរស្រាលឡើងវិញមួយនាទីដែរ។

«ជំនួយមកហើយ! ពួកគេនៅតាមផ្លូវឈប់ភ័យទៅ!»

ខ្ញុំនិយាយលោមក្មេងស្រីជំទង់ដែលទ្រោបស្រែកយំ។

ស្នូរជើងហ្សេដារត់មកពីចម្ងាយ។

ខ្ញុំចង្អុលទៅក្មេងនោះ គាត់ក៏ឡើងរថយន្តរបស់នាង។

ដោយសារមន្ទីរពេទ្យដែលនៅជិតបំផុត គឺត្រូវការបើកបររយៈពេលសែសិបនាទី យើងត្រូវបង្ខំឱ្យប្រើគ្លីនិកស្រុកស្រែតូចមួយសម្រាប់អ្វីៗគ្រប់យ៉ាងពេលនេះ។

ដោយសារសភាពនាងជំទង់មិនបានគំរាមកំហែងដល់អាយុជីវិត យើងត្រូវនាំយកនាងមកគ្លីនីកស្ថិតនៅចុងម្ខាងទៀតនៃទីក្រុង ដែលជាផ្លូវល្អប្រើការបើកបរម្ភៃនាទី តែ....ផ្លូវងងឹត និងស្ងាត់ជ្រងំ។ អរគុណព្រះជាម្ចាស់ ផ្លូវលេខ 199 នៅម៉ោង 3:00 ទៀបភ្លឺ នេះមិនបានស្ទះចរាចរណ៍ទេ ។

«ប្រាប់ហើយថា បើលោកខែទៅជាបែបនេះ រឿងនិទានចាស់នឹងរស់ឡើងវិញ!»

ហ្សេដារអ៊ូបណ្ដើរពេលដើរកាត់ខ្ញុំ ឆ្ពោះទៅបើកទ្វារឡានខាងណោះនាំយកក្មេងស្រីជំទង់ទៅសង្គ្រោះបឋម។

សម្ដីព្រមានរបស់ហ្សេដាដែលគ្មានអ្នកណារវល់ពេលនេះរត់ពេញក្បាលខ្ញុំ។ សត្វចចកបានក្លាយជាបញ្ហាពិតមែនឬ?

ផ្អែកតាមទិន្នន័យព័ត៌មានអាមេរិក ទំហំសហគមន៍ចចកនាពេលថ្មីៗនេះ ក៏មានកំណើនឡើងគួរឱ្យបារម្ភ។ សត្វនេះបានដើរតាមស្វែងរកអាហារ ដូចជាតាមពីក្រោយហ្វូងសត្វក្តាន់យ៉ាងប្រកិតនិង

បញ្ចេញសកម្មភាពយ៉ាងគ្រោះថ្នាក់ ឆ្លើយតបទៅនឹងចិត្តសប្បុរស អភិរក្សពូជសត្វរបស់នាយកដ្ឋានធនធានធម្មជាតិ។

ទោះយ៉ាងណាក៏ដោយ ចចកមិនដូចឆ្កែធម្មតាទេ។ ប្រសិនបើត្រូវរបួសដោយធ្មេញឬចង្កូមវា មិនចាំបាច់ចាក់ថ្នាំឆ្កែឆ្កួតដូចត្រូវសុនខធម្មតាខាំឡើយ។

«អ្នកណាខាំនាង?» ពេទ្យចាប់ផ្តើមកត់ត្រា។ ក្មេងនៅរន្ធត់និងខ្សោយព្រោះឈឺចាប់ ខ្ញុំដែលដឹងចម្លើយ ក៏និយាយឡើង៖

«នាងប្រាប់ខ្ញុំឆ្កែ» ។

«អាឆ្កែធំ» ពេទ្យសម្លឹងចង្កូមហើយរអ៊ូ។

«ចាស៎ ធំណាស់! វាធំមែនទែន» ខារ៉េនដាច់ចិត្តបន្ទរឡើង ព្រោះនាងញ័រពេលនឹកឃើញព្រឹត្តិការណ៍។ ពេលពួកយើងគ្រប់គ្នានៅផ្ងង់ស្តាប់នាងក៏បន្តនិទានឡើងទាំងមាត់រញ៊ីរញ័រ៖

«វារត់មកពាំងខាងមុខឡាន! វាខ្មៅងងឹតដូចយប់! ខ្ញុំដេញវា វាមិនព្រមទៅណាទេ មិនទៅសោះ!»

នាងងក់ក្បាល រួចថ្ងូរឈឺ ភ្នែកហាក់ដូចជាគិតវង្វេងភ័យនឹងសកម្មភាពពេលនោះនៅឡើយ។

«ម៉េចបានខាំ?»

«ខ្ញុំគិតថា ស្មានថាខ្ញុំបុកវាស្លាប់ហើយ» ។

ក្មេងជំទង់និយាយធ្វើឱ្យខ្ញុំនឹកឃើញដល់ល្បិចចចក ដែលជាសំណៅនិទានល្អត្រូវចងចាំនៅពេលទាក់ទងជាមួយសត្វព្រៃ។ វាមិនខុសពីមនុស្សអាក្រក់ក្នុងរឿងល្ខោនទេ ជាធម្មតាពួកវាមិនស្លាប់ប៉ុន្តែលេងល្បិចធ្វើពុតដាក់យើងនឹងអាលបានឆ្នក់។

ខ្ញុំមិនធុំក្លិនគ្រឿងស្រវឹងលើខ្លួនក្មេងនេះទេ ប៉ុន្តែនាងត្រូវបានគេពិនិត្យរកសារធាតុញៀន នៅគ្លីនិកដដែល។ ខ្ញុំប្រញាប់ឆែក កាបូបលុយនាង។ នាងឈ្មោះពេញ Karen Larson ហើយការចុះឈ្មោះក្នុងបណ្ណបើកបរ បញ្ជាក់ថានាងជាម្ចាស់រថយន្ត។

«យើងទៅរកឆ្កែនោះមក!»

ហ្សេដារអ៊ូគិត។

«ទុកវាទៀតនាំតែវាខាំគេផ្សេង! មនុស្សមកលេងច្រើនឡើងៗ!» គាត់បន្ថែមដោយចរិតជាប៉ូលិសមានការទទួលខុសត្រូវ។

ខ្ញុំងក់ក្បាល៖

«ខ្ញុំទៅ! មីងនៅទីនេះចាំចុះ រង់ចាំដល់ម្តាយឪពុកនាងមកទទួលនាង!»

ខ្ញុំចាកចេញក្រោមការកោតសរសើររបស់កែវភ្នែកហ្សេដាហាប់មិន។

«ប្រយត្ន័ផងជេស៊ី!» គាត់ស្រែកតាមមកពីក្រោយ។ ដៃខ្ញុំស្ទាបកាំភ្លើងនិងខ្នោះលើចង្កេះ។ ខ្ញុំចុចឡានពីចម្ងាយ។

គ្រាំង!

វាជាទម្លាប់បិទទ្វារឡានរបស់ប្រេដ(Brad) មិត្តរួមការងារខ្ញុំម្នាក់ដែលរមែងតែងបានមកដល់ចុងក្រោយគេ ពោលគឺពេលឆាកប្រយុទ្ធនីមួយៗចប់។

ប្រេដមានវ័យក្មេង ចិត្តអន្ទះសានិងអង់អាច។ នៅអាមេរិក ឈ្មោះថាប៉ូលិសតាមរដូវគឺមានន័យថា មកថែទាំរក្សាការពារអ្នកទេសចរ ហើយក៏មិនមែនជាប្រជាជនមកពីតំបន់នេះដែរ។ អំឡុងពេលប្រាំបួនខែផ្សេងទៀតនៃឆ្នាំនីមួយៗ ខ្ញុំគិតថា ចំណាយពេលតែនឹងការលើកទម្ងន់យកសាច់ដុំ រក្សា 6 pack ហើយអាំងយកស្បែកខ្មៅក្រោមពន្លឺព្រះអាទិត្យសិប្បនិម្មិតដើម្បី«ឡូយ»។

ពេលចេញមកក្រៅ ខ្ញុំបានជួបប្រេដ នៅពាក់កណ្ដាលផ្លូវរវាងឡានរបស់គេនិងឡានខារ៉ែន ។

«អស់សំណើចណាស់ មានឆ្កែចចកខាំ?» ខ្ញុំមិនមានពេលសម្រាប់ chitchat ទេ។ មិនមែនមានន័យថាខ្ញុំនឹងរំខានចិត្តសូម្បីតែបានប្រុសស្អាតនិយាយរកឡើយ តែខ្ញុំចាញ់សម្រស់ប្រេដ។

«ទុកស្រីស្អាតកូនអ្នកមានឱ្យខ្ញុំ! ខ្ញុំនឹងពិនិត្យមើលថា អាចចកអាល់ហ្វាណាមួយ!»

គេថាហើយសើចកក្អៀក។ ពេលត្រូវខ្ញុំធ្វើប៉ុយដើរហួសទៅប្រេដមិនព្រមឈប់ទៀត៖

«Jessie អ៊ីចេះក៏ល្អ ខ្ញុំនឹងរក្សានាងតូចស្អាត ឯ Jessie ឯងទទួលចំណែកអាខាងរុករកចាប់ស្ដេចចចកមួយក្បាលត្រោលហ្នុងមកមើលមើល៍ ក្រែងសង្ហាដូចក្នុងរឿងនិទាន? »

ខ្ញុំឈប់ក្បែរទ្វារសម្លក់ប៉ូលិសអណ្ដែតដែលរលោម។ ប្រេដញាក់ស្មាឱមកខ្ញុំដដែល៖

«នៅកណ្ដាលយប់នៅក្នុងព្រៃក្រោមពន្លឺខែខ្មៅមួយ ហើយសត្រូវរបស់យើងអាចនឹងក្លាយជាចចកពិសេសមួយ ដែលស្រីៗអ្នកអានប្រលោមលោកកំពុងងប់ចិត្តស្វែងរក»

ខ្ញុំដឹងហើយថា នោះឯងជាមូលហេតុដែល Brad ធ្វើជាប៉ូលិសរដូវក្ដៅហើយមានពេលសម្រាក ឯខ្ញុំជាប៉ូលិសពេញមួយឆ្នាំហត់អើយហត់ព្រោះខ្ញុំតែងតែទៅពេលមិនទាន់ដោះស្រាយរួច ឯគេមកដល់ហើយពេលសាច់រឿងស្ងប់ហើយ គេក៏ចៀរយកចំណែកល្អទៅ ទុកចំណែកអន់ឱ្យខ្ញុំ។ ខ្ញុំមិនឆ្លើយទេ គេនេះដូចអ្នកឯទៀតដែរ មើលមកខ្ញុំគ្មានសម្រស់អីទាំងអស់។

«នីតិវិធីស្ដង់ដារនៅពេលដោះស្រាយជាមួយសត្វចចក គឺ ត្រូវហៅប៉ូលិសប្រមាញ់មក!»

គេស្រែកប្រាប់ខ្ញុំពីក្រោយខ្នងទៀត ខ្ញុំបិទទ្វារឡាន។ ប្រេដពូកែចំអកណាស់ ស្មានថាខ្ញុំមិនហ៊ានជាមួយចចកហើយមើលទៅ?

ឆ្កែចចកបានក្លាយជាប្រភេទសត្វជិតផុតពូជនៅក្នុងរដ្ឋ Wisconsin រហូតដល់ឆ្នាំ 1999 នៅពេលដែលការចាត់ថ្នាក់ត្រូវបានផ្លាស់ប្ដូរ ព្រោះពួកគេទទួលការគំរាមកំហែងពីពួកមនុស្សប្រមាញ់គ្មានមេត្តា។

ថ្មីៗនេះ ពួកគេបានបង្កើនចំនួនឡើងវិញ ព្រោះការសន្តោសការពារក្រោមច្បាប់។

បើខ្ញុំត្រូវបាញ់ចចកយប់នេះ ខ្ញុំនឹងធ្វើ! ខ្ញុំសម្រេចចិត្តរួចហើយពេលឃើញអាការៈស្លន់របស់ខារ៉ែន។

ក្នុងរយៈពេលម្ភៃប្រាំមួយឆ្នាំរបស់ខ្ញុំ ដែលមានវត្តមានលើផែនដីនេះខ្ញុំទទួលបានការចំអកនិងត្រូលឆ្អែតហើយ។ ហើយមួយក្នុងចំណោមមនុស្សអស់នោះ ភាគច្រើនយល់ថាខ្លួនគេក្លាហានជាងខ្ញុំដឹង? តែខ្ញុំមិនជឿទេ។

«ប្រេដជាអ្នកប្រមាញ់ដ៏ល្អបំផុតនៅក្នុងកងកម្លាំងយើងដែលគេបញ្ជូនមកនេះ!»

ហេរ្សដាប្រាប់តាមវិទ្យុទាក់ទងតែខ្ញុំមិនសើចចេញទេ។ ខ្ញុំនិយាយម្នាក់ឯង៖

«ប្រមាញ់ព្រះនាងៗ»

«ម៉េចដឹង?»

ខ្ញុំភ្ញាក់ព្រោះគេឮខ្ញុំនិយាយឆ្លងឆ្លើយអំពីគេជាមួយហេរ្សដា។ ប្រេដចូលមកអង្គុយក្នុងឡាននេះពីក្រោយខ្ញុំ បានន័យថា គេស្ម័គ្រទៅលើភ្នំវិញជាមួយខ្ញុំ?

ការពិតដែលមិនធ្វើឱ្យខ្ញុំអស់សង្ឃឹមគេពេលនេះគឺ គេមានភាពជាបុរសខ្លះដែរ។

គួរសម! ខ្ញុំសរសើរគេហើយរ៉ុយែរឡានបើកបោលចេញយ៉ាងលាន់ឮនិងយ៉ាងជំនាញ។ ហោចណាស់មានប្រុសស្អាតដូចគេមកដែរ បេសកកម្មនេះ គួរសម!

តាមដានក្លិនឈាម ជាមេរៀនដែលពួកយើងម្នាក់ៗរៀនចាំស្ទាត់ និងហ្វឹកហាត់ខុសរាប់ភ្លេចហើយ មុនពេលអាចមកឈរជើងជាប៉ូលិសព្រៃ។ ឥឡូវនេះ នៅក្នុងភាពងងឹត គឺជាល្បិចមួយ ខ្ញុំបិទភ្នែកផ្ទង់លើច្រមុះ។

«នៅចាំក្នុងឡានល្អទេ ចាំខ្ញុំហៅ ឈើអស់នេះខ្ញុំស្គាល់!» ប្រេដថាមកខ្ញុំទាំងភ្នែកគេសែនរំពៃដៃគេកាន់កាំភ្លើងណែន។

«ចំអកខ្ញុំពេលនេះ ឬចង់ទុកចំអកទៅពេលក្រោយ?»

ខ្ញុំថាហើយកៀកស្មាទៅតាមគេបង្ហាញថា ក្នុងចំណោមបញ្ជីប៉ូលិសកំសាកគ្មានឈ្មោះខ្ញុំទេ។

ជាមួយនឹងសំឡេងរាត្រីកាលក្រោមសន្ទឹកជំនោរអាថ៌កំបាំងដ៏ស្រៀវស្រើប ព្រៃបានបិទជុំវិញពួកយើង បន្សល់ទុកនូវពិភពដ៏ស៊ីវិល័យនៃរថយន្ត និងភ្លើងអគ្គិសនី នៅឯផ្លូវនៅខាងក្រោយឆ្ងាយសន្លឹម។

ពួកយើងមកជ្រៅហើយ។

នៅក្រោមដំបូលនៃដើមឈើបៃតងងងឹតស្លុប ខ្ញុំស្ទើរតែមិនអាចមើលឃើញផ្កាយ។ នោះហើយជារបៀបដែលប៉ូលិសជាច្រើនធ្លាប់បានបាត់បង់ស្មារតីក្លាហាន ចាញ់ភាពងងឹត។ ខ្ញុំបានរៀននៅក្នុង

ឆ្នាំដំបូងៗនៅជុំវិញហ្វឹកហ្វឺនអំពីកម្លាំងរឿងមនុស្សមួយចំនួនដែលតែង បាត់ខ្លួនព្រោះដើរចូលព្រៃចាប់ចចក ហើយក្នុងនោះក៏មានប៉ូលិសយើងដែរ។ ពួកគេមិនដែលវិលមកក្រៅវិញឡើយ។

តែ......មិនមែនខ្ញុំទេ។

ខ្ញុំមានពិល កាំភ្លើង និងត្រីវិស័យរបស់ខ្ញុំនឹងក្រពះមួយដែលថ្មឹកនឹងការអត់អាហារបានយូរ។ ខ្ញុំអាចជាប់គាំងនៅទីនេះជាច្រើនថ្ងៃ ហើយក៏នៅតែរកផ្លូវទៅផ្ទះវិញបាន ទោះគ្មានប្រេដក៏ខ្ញុំមិនព្រមចាញ់ឱ្យគេចំអកដែរ។ ខ្ញុំមិនមែនការពារពោតដុះទេ ខ្ញុំចាប់ចចក។

ភាពមោទនភាពនេះបង្កើនទឹកចិត្តដល់ខ្ញុំឱ្យរុលទៅៗ។ អ្វីដែលខ្ញុំត្រូវការគឺចូលទៅឱ្យជិតទីលាក់ខ្លួននៃឆ្កែចចក ហើយឱ្យហ្សេដាបញ្ជូនរលកសញ្ញាទៅអ្នកក្រុមប្រមាញ់ ខ្ញុំនឹងមានឱកាសឡើងឋានៈ។

ខ្ញុំប្រាថ្នាគិតដែរអំពីកាំភ្លើងវែងៗ។ នៅទីនេះខ្ញុំមានមកជាមួយតែនឹងកាំភ្លើងខ្លីតែ ខ្ញុំត្រូវការចូលឱ្យកៀកជិតខ្លាំង ប៉ុន្តែយើងមានវិន័យ រក្សាអាវុធវែងនៅក្នុងឃ្លាំងសុវត្ថិភាព និងរឹតបន្តឹងពេកណាស់នៅឯស្ថានីយ៍ប៉ូលិស។

ក្លិនឈាមបានបញ្ឆោឱ្យខ្ញុំបត់ស្តាំ បន្ទាប់មកឆ្វេង បន្ទាប់មកស្តាំម្តងទៀត។ ព្រះចន្ទកំពុងបញ្ចេញពន្លឺ ជាពន្លឺគួរឱ្យខ្លាចដូចរឿងនិទានដែលហ្សេដាជឿ ក៏ជាប្រភេទពន្លឺខែបិសាចនៃរាត្រីកម្រ ដែលសត្វភាគច្រើនរកទីលាក់ខ្លួនភ័យ លើកលែងតែសត្វចចក ដែលចាស់ៗនិទានថា វានឹងមានឫទ្ធិខ្លាំងក្នុងវេលាបែបនេះក្រោមពន្លឺព្រះចន្ទពណ៌នេះ។

យប់នេះ ខ្ញុំក៏ដូចជាមានអារម្មណ៍ចូលចិត្តពន្លឺចន្ទនេះដែរ ដោយសារពណ៌ប្រាក់ទែងរបស់វាចេញពីស្នាមភ្លឺចែងចាំងនៅលើដី និងស្លឹកឈើនៅជុំវិញព្រៃ។ ឈាមនៅតែជះក្លិន បានផ្តល់ឱ្យខ្ញុំសង្ឃឹមថាកន្លែងយកសក្តិរបស់ខ្ញុំប្រហែលជានៅមិនឆ្ងាយពេកទេ។ ចចកអាចនឹងស្លាប់ទៅទៀតផងព្រោះឈាមច្រើន ហើយមិនមែនជាក្លិនឈាមមនុស្សសុទ្ធសាធទេ។

ទោះយ៉ាងណាក៏ដោយ ខ្ញុំបានក្តាប់រក្សាកាំភ្លើងខ្លីយ៉ាងប្រុងប្រៀបក្នុងបាតដៃទាំងសង។ ប្រេដបាត់ទៅទិសផ្សេងហើយ។ ខ្យល់បក់បោកខ្លាំងមកទាំងមិនសមសោះ វាយរប៉ាយសក់ក្រេងដែលខូចរញ៉េរញ៉ៃព្រោះការហត់នឿយមួយនេះ។ ខ្ញុំក៏ឈប់ដើរសិនហើយងើបមុខសម្លឹងយប់ដែលក្រភ្លឺ រួចដេរខ្សឹបៗធុញទ្រាន់រកទីតាំងសត្វមិនឃើញ។

ខ្យល់បក់ខ្លាំងឡើងៗ.....អ្វីមួយខ្សឹបប្រាប់ញាណខ្ញុំថា បើចចកគ្រោសនោះ មិនទាន់ស្លាប់ទេ គេដឹងថា ខ្ញុំមក គឺសំឡេងព្រមានដោយប្រាជ្ញាខ្ញុំខ្លួនឯង។

ភ្លាមនោះ.....សំឡេងយំច្ងូរមួយ.....លាន់មកពីឆ្ងាយ ត្រូវបានក្ងួចឡើងលើមេឃតាមកម្លាំងខ្យល់ និងបក់កាត់ភាពងងឹត រួចរត់ទៅរកពន្លឺព្រះចន្ទ។ ខ្ញុំជ្រែងជើងឈប់ស្ងៀមផ្ទៀងស្តាប់។ នេះមិនមែន

ជាសំឡេងសត្វដែលកំពុងស្វែងរកគូ ថ្ងូរព្រោះតណ្ហារងាទេ តែជាសំឡេងស្រែកថ្ងូរយ៉ាងក្តៅគគុករបស់សត្វឈ្មោលគួរតែមានរាងធំ ដែលធ្វើឱ្យខ្ញុំចេះពិភាល់ភ័យ។

ចចកដឹងខ្ញុំមក ហើយវាបានត្រៀមខ្លួនទទួលប៉ូលិសហើយ។ ខ្ញុំគិតទាំងបើកភ្នែកក្រឡឹងខ្លួនឯងមួយជុំរំពៃយ៉ាងមុត។ ក្លិនឈាមឈ្មៀមបានជះមកតាមខ្យល់មួយរឹប ខ្ញុំបានលោតប្រដេញចូលធ្វើចលនាលឿនជាងមុន ឆ្ពោះទៅទីនោះ ចាប់សត្រូវនិងបញ្ចប់រឿងនេះ។

ប៉ុន្តែក្លិនឈាមរសាត់បាត់! វាមិនស្រួលទេ! ក្លិនបាត់យើងក៏បាត់គោលដៅដែរ ខ្ញុំឈានថយក្រោយបន្តិចផ្ទង់ស្រង់ក្លិនរកមើលសំណាកសេសសល់របស់ឈាមនោះ នៅតែបាត់ដាន! មិនឃើញអ្វីសោះ។

ឈាមចចកត្រោស ដូចជាបានបាត់ខ្លួនទៅក្នុងស្រទាប់ខ្យល់ស្តើងបាន។ កន្ទុយភ្នែកខ្ញុំបានក្រឡេកឃើញស្រមោលមួយរំកិលពីគល់ឡើងទៅលើដើមឈើ។

សំឡេងភ័យមួយខ្សឹបនឹងខ្ញុំ....តើចចកប្រភេទណាអាចឡើងដើមឈើបាន? មិនមែនជាចចកដែលខ្ញុំចង់ជួបទេអ៊ីចឹងនោះ។

ចលនាមួយនៅខាងមុខ បានធ្វើឱ្យខ្ញុំងាកមកឆ្វាច់ហើយសម្លឹងផ្តោតទៅ។ ចលនាបាត់ទៅវិញត្រឹមមួយក្រឡេកសោះ ឯការសម្លឹងសេសសល់របស់ខ្ញុំបានចប់នៅត្រង់គុម្ពោតព្រៃដែលនៅរង្កើទងផ្កានិងកូនឈើតិចៗ.....ខ្ញុំឃើញកូន បង្អួចនៃកាប៊ីនមួយងងឹតស្លុប។

ប្រសិនបើខ្ញុំសំណាង កាប៊ីននេះមានអ្នកនៅ។ តែ ខ្ញុំមិនចង់បំភ័យអ្នកណាដោយការបាញ់កាំភ្លើងនៅខាងក្រៅផ្ទះថ្មីព្រៃរបស់ពួកគេ វេលាម៉ោង ៤ ទៀបភ្លឺទេ។

តំណក់ឈាមដ៏ភ្លឺថៃងចាំងនៅលើស្លឹកមួយក្រោយគេ បានធ្វើឱ្យខ្ញុំគោះកៃកាំភ្លើងខ្លីរបស់ខ្ញុំ។ ព្រៃឈើ ខ្យល់និងទិដ្ឋភាពនានានៅស្ងៀមឈឹង។ ខ្ញុំតានតឹងចិត្តជាខ្លាំងព្រោះកំពុងគិតថា ខ្ញុំអាចដែរគ្រាន់តែមិនដឹងថា មានអ្វីនៅទីនោះ ជាឈាមអ្នកណា ក៏បាញ់ផ្អើលព្រៃឱ្យប្រែដរត់មកចំអក?

ប៉ុន្តែ....ចុះយ៉ាងណាទៅ បើឆ្កែចចកលោតចេញមកមុនហើយហក់ហែកកំទេចមុខ និងខាំស៊ីថ្គាមខ្ញុំខ្ទេចខ្ទីមុនពេលខ្ញុំកេះកៃបាញ់?

ការសម្រេចចិត្ត! ការសម្រេចចិត្ត! ខ្ញុំស្អប់ការសម្រេចចិត្ត!

«ហេ!» ខ្ញុំស្រែកឡើង សង្ឃឹមថាចចកនឹងព្ន វាចេញមកស្លន់និងរត់ទៅផ្លូវផ្សេង ហើយខ្ញុំអាចបំបាញ់។

តែ.....មិនដូចគម្រោងទេ! បែបគ្មានសំណាងដូចការស្រមៃឡើយ! ព្រៃចាប់ផ្តើមញ័រម្តងទៀតហើយស្រមោលមួយបានលូតឡើង វែងឡើង កាន់តែធំ និង.....មានរាងជាមនុស្ស។

មើលពីនេះទៅ គេជាបុរសម្នាក់! រាងគេពិតជាណែននិងសង្ហា។ ឫកពាឈរជាប្រុសស្អាត តែ.....រាងកាយគេអាក្រាត។

អានបន្តរៀងរាល់ថ្ងៃចន្ទដោយចូលជាសមាជិក PREMUIM